ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ.១៥៨/១៧

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែ១០ ឆ្នាំ២០១៧

## សូមគោរពជូន
## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
## នៃព្រះរាជាណាចក្រកម្ពុជា

**កម្មវត្ថុ:** សូមគោរពស្នើសុំគោលការណ៍អនុញ្ញាតដ៏ខ្ពង់ខ្ពស់ដើម្បីរៀបចំទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ ធ្នូ ឆ្នាំ២០១៧ *នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ* និងសូមគោរពអញ្ជើញ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ជាគណៈអធិបតីដ៏ខ្ពង់ខ្ពស់។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមគោរពជម្រាបជូន **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា: គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នឹងរៀបចំប្រារព្ធទិវាជាតិប្រឆាំងការជួញដូរមនុស្ស នៅថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ២០១៧ ដែលជាឆ្នាំទី១១ សម្រាប់ **ព្រះរាជាណាចក្រកម្ពុជា**។ កម្មវិធីទិវាជាតិប្រឆាំងការជួញដូរមនុស្សឆ្នាំនេះ នឹងប្រារព្ធធ្វើ *នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ* ដែលមានអ្នកចូលរួមពីគ្រប់ក្រសួង-ស្ថាប័នក្នុងរាជរដ្ឋាភិបាល និងប្រជាពលរដ្ឋ ប្រមាណ ៣០០០នាក់ ដើម្បីជាយុទ្ធនាការរួមគ្នាបង្កើតនូវប្រព័ន្ធសុវត្ថិភាព និងពង្រឹងការអនុវត្តច្បាប់អោយកាន់តែរឹងមាំ សម្រាប់ការពារប្រជាពលរដ្ឋអោយរួចផុតពីភាពងគ្រោះដោយអំពើជួញដូរមនុស្ស ដែលជាធនធានដ៏មានសក្តានុពលក្នុងការពង្រឹង និងពង្រីកខឿនសេដ្ឋកិច្ចដ៏ល្អប្រសើរ ដើម្បីបោះជំហានទៅមុខ ឆ្ពោះទៅកាន់ចក្ខុវិស័យរួមគឺ **"កម្ពុជាព្រះរាជាណាចក្រអច្ឆរិយៈ"**។

ដើម្បីអោយទិវាជាតិប្រឆាំងការជួញដូរមនុស្ស ឆ្នាំ២០១៧ នេះ ប្រព្រឹត្តទៅប្រកបដោយបរិយាកាសអធិកអធម និងរឹតតែមានអត្ថន័យជ្រាលជ្រៅ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) សូមគោរពអញ្ជើញ **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** មេត្តាផ្តល់កិត្តិយសអញ្ជើញជាគណៈអធិបតីដ៏ខ្ពង់ខ្ពស់ ដើម្បីថ្លែងសារជានយោបាយដ៏មានសារៈសំខាន់ជូនជនរួមជាតិ និងដើម្បីតម្រង់ទិសឲ្យគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បន្តដឹកនាំការអនុវត្តសកម្មភាពឲ្យរឹតតែមានប្រសិទ្ធភាពខ្ពស់។

អាស្រ័យហេតុដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ៕

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

សម្តេចក្រឡាហោម ស ខេង

17-10-17

19/10/17